**ក្រោយពីបានស្ដាប់សេចក្ដីរាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់រួចហើយ**

-យល់ឃើញថា ការសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះដោយប្រធានរដ្ឋសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លា ទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ចំណុចដែលបានកែប្រែមានជាអាទិ៍ដូចតទៅ ÷

១-ការកែប្រែអាជ្ញាយុកាល ( មាត្រា ៣ ថ្មី ) គឺអាជ្ញាយុកាលនៃពាក្យបណ្ដឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំ តទៅទៀត ( រីឯមាត្រា ៣ ចាស់ អាជ្ញាយុកាលនេះ ត្រូវបានពន្យារពេលបន្ថែម ២០ ឆ្នាំ ទៀតតែប៉ុណ្ណោះ ) ។

២-ការកែសម្រួលរចនាសម្ព័ន្ធសាលាជម្រះក្ដី ( មាត្រា ៣ ថ្មី ) គឺរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញដែលមាន ៣ ថ្នាក់ ត្រូវបានសម្រួលមកត្រឹម ២ ថ្នាក់ គឺសាលាដំបូង និង តុលាការកំពូល ( តុលាការកំពូលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផង និងសម្រេចសេចក្ដីចុងក្រោយផង ) ។

៣-ការកែប្រែសមាសភាពនៃអង្គជំនុំជម្រះតុលាការកំពូលឱ្យមានចៅក្រមខ្មែរ ៤ រូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមអន្តរជាតិ ៣ រូប ។ អង្គជំនុំជម្រះតុលាការកំពូលនេះ សម្រេចសេចក្ដីបិទផ្លូវតវ៉ា ( មាត្រា ៩ ថ្មី ) ។

៤-ការកែប្រែអំពីសិទ្ធិពេញលេញរបស់ជនជាប់ចោទ និង អភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការ និង មេធាវី ដោយផ្អែកលើអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ( មាត្រា ៤២ ថ្មី ) ។

៥-ការកែប្រែបន្ថែមអំពីនីតិវិធីឱ្យបានច្បាស់ថែមទៀតដូចតទៅនេះ : " ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងអំពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របនៃនីតិវិធីទាំងអស់នេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ " ( មាត្រា ២០ ថ្មី មាត្រា២៣ ថ្មី ) ។

៦-ការចែងបន្ថែមអំពីវិសាលភាពនៃការលើកលែងទោស និង អនុគ្រោះទោសដែលអាចផ្ដល់ឱ្យមានមុនការអនុម័តច្បាប់នេះ គឺសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ( មាត្រា ៤០ ថ្មី ) ។

៧-ការចែងបន្ថែមអំពីល័ក្ខខ័ណ្ឌចៅក្រមដែលត្រូវតែងតាំង ហើយបំរើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវមានបទពិសោធន៍រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង ( មាត្រា ១០ ថ្មី ) ។

៨-សហព្រះរាជអាជ្ញាបរទេស មានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងបរទេស ( មាត្រា ២២ ថ្មី ) ។

៩-ការចែងបន្ថែមអំពីភាពមិនអាចរំលោភបំពានបាននៃបណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និង ជាទូទៅឯកសារ និង

សម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬ ប្រើប្រាស់ដោយជនណាក៏ដោយក្នុងរយៈពេលនៃដំណើរការជំនុំជម្រះនេះ ( មាត្រា ៤២ ថ្មី ) ។

១០-ការកាត់បន្ថយការប្រើប្រាស់ភាសាជាផ្លូវការមកត្រឹម ៣ ភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ( មាត្រា ៤៥ ថ្មី ) ។

១១-ការកែប្រែដោយលុបចោលបទបញ្ញត្តិដូចតទៅ :

-លុបពាក្យ " មូលនិធិស្ម័គ្រចិត្ត " នៅក្នុងចំណុចទី ២ នៃមាត្រា ៤៤ ចាស់

-លុបចំណុចទី ៣ នៃមាត្រា ៤៤ ចាស់ ។

ចំណុចកែប្រែទាំង ១១ ខាងលើ និងចំណុចកែប្រែដទៃទៀត ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនេះ ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែមាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទិ ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំ រេ ច

**មាត្រា ១ .-**

មាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៤ ថ្មី : ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសមាសភាពដូចតទៅ :

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន
- រដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងផែនការ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន សមាជិក
- រដ្ឋលេខាធិការ នៃក្រសួង យុត្តិធម៌ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ សមាជិក
- រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី សមាជិក
- ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក
- តំណាងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- អគ្គលេខាធិការ គណៈកម្មការជាតិវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

អនុប្រធានអចិន្ត្រៃយ៍

**សុខ អាន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៩...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការបង្កើតតំបន់អភិវឌ្ឍន៍រុនតាឯក

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បី ការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា" ឱ្យស្របជាមួយបទបញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.-**

បង្កើតតំបន់អភិវឌ្ឍន៍មួយ ដាក់ឈ្មោះថា " **តំបន់អភិវឌ្ឍន៍រុនតាឯក** " ។

**មាត្រា២.-**

ទីតាំងនៃតំបន់អភិវឌ្ឍន៍ ស្ថិតនៅក្នុងភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី និងក្នុងភូមិស្នាសង្គ្រាម ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ តំបន់អភិវឌ្ឍន៍នេះមានទំហំដីចំនួន **មួយពាន់ដប់ពីរ ក្បៀសប្រាំ** (១ ០១២. ៥ ) **ហិកតា** ស្ថិតនៅត្រង់ចន្លោះចំណុចដូចខាងក្រោម :

-ចំណុច **ក** ខ្សែរយៈបណ្តោយ **៣៩៤ ០០០** និងខ្សែរយៈទទឹង **១ ៤៩២ ០០០**

-ចំណុច **ខ** ខ្សែរយៈបណ្តោយ **៣៩៨ ៥០០** និងខ្សែរយៈទទឹង **១ ៤៩២ ០០០**

-ចំណុច **គ** ខ្សែរយៈបណ្តោយ **៣៩៨ ៥០០** និងខ្សែរយៈទទឹង **១ ៤៨៩ ៥២០**

-ចំណុច **ឃ** ខ្សែរយៈបណ្តោយ **៣៩៤ ០០០** និងខ្សែរយៈទទឹង **១ ៤៨៩ ៨០០**

**មាត្រា៣.-**

តំបន់អភិវឌ្ឍន៍នេះត្រូវបានប្រគល់ជូនអាជ្ញាធរអប្សរា ជាអ្នកគ្រប់គ្រង និងរៀបចំការអភិវឌ្ឍន៍តាមទិសដៅរបស់រាជរដ្ឋាភិបាល និងក្នុងការងារដោះស្រាយបញ្ហាសំណង់លំនៅដ្ឋានថ្មីរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅ ក្នុងតំបន់១ និងតំបន់២ នៃរមណីយដ្ឋានអង្គរសព្វថ្ងៃ ។

**មាត្រា៤.-**

អាជ្ញាធរអប្សរា ជាអ្នកទទួលបន្ទុករៀបចំប្លង់អភិវឌ្ឍន៍តំបន់នេះ ដើម្បីបង្កលក្ខណៈងាយស្រួល ជូនដល់ប្រជាពលរដ្ឋ ដែលត្រូវចេញពីតំបន់អង្គរទៅរស់នៅក្នុងតំបន់នោះ អាចរស់នៅបានយ៉ាងសមរម្យនិង មានការអភិវឌ្ឍន៍នាពេលអនាគត ។

**មាត្រា៥.-**

អាជ្ញាធរអប្សរាជាអ្នកទទួលបន្ទុកចុះអង្កេតរាល់ការកាន់កាប់ និងប្រើប្រាស់ដី នៅក្នុងតំបន់នេះ របស់ប្រជាពលរដ្ឋ ហើយសហការជាមួយអាជ្ញាធរដែនដី ដើម្បីដោះស្រាយគោលនយោបាយឱ្យបាន សមស្រប ។

**មាត្រា៦.-**

អនុក្រឹត្យនេះ និរាករណ៍រាល់លិខិតពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីក្នុងតំបន់នេះ ដូចមានភ្ជាប់ប្លង់ក្នុងឧបសម្ព័ន្ធ ១ ។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- កាលប្បវត្តិ-ឯកសារ


Tum
Thnal
anghout
Ta Ni
ey
ក
ខ
គ
ឃ
២៥ហត
១៥ហត
១០ហត
ភូមិតាទី
ព្រំប្រទល់ភូមិតាទី
និងភូមិស្នាសង្គ្រាម
ភូមិស្នាសង្គ្រាម
កូដ X Y
ក ៣៩៤០០០ ១៤៩២០០០
ខ ៣៩៨៥០០ ១៤៩២០០០
គ ៣៩៨៥០០ ១៤៨៩៥២០
ឃ ៣៩៤០០០ ១៤៨៩៨០០

# តំបន់អភិវឌ្ឍន៍_រុនតាឯក



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន

## ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦១ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាសភាព អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយ សារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយ សារមីន
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៤

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ដោយកំណត់បន្ថែមនូវតួនាទីរបស់អាជ្ញាធរគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ហៅកាត់ថា អាជ្ញាធរមីន និងតួនាទីអាជ្ញាធរ ខេត្តក្រុងពាក់ពន្ធ័ ព្រមទាំងអង្គការអភិវឌ្ឍន៍នានា ដើម្បីជួយសំរួលដល់ដំណើរការ បោសសំអាតមីន ផ្នែកសេដ្ឋកិច្ច-សង្គម។

## ជំពូកទី ២

## ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

**មាត្រា ២.-**

អាជ្ញាធរមីន មានសមត្ថកិច្ចត្រួតពិនិត្យគ្រប់សកម្មភាពកំចាត់មីនទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវប្រសិទ្ធភាព សកម្មភាពបោសសំអាតមីន ដូចមានកំណត់ក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ព្រមទាំងផែនការដទៃទៀតរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុង ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន។

**មាត្រា ៣.-**

អាជ្ញាធរមីន សំរបសំរួលសកម្មភាពកំចាត់មីនជាមួយក្រសួង ស្ថាប័ន និង ណែនាំបច្ចេកទេសអាជ្ញាធរដែនដីពាក់ព័ន្ធ ក្នុងការអនុវត្តយុទ្ធសាស្ត្រ និង ផែនការជាតិនៃសកម្មភាពកំចាត់មីន ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ។

**មាត្រា ៤.-**

អាជ្ញាធរមីន ពិនិត្យលើសំណើតាមអាទិភាព ដែលស្នើឡើងដោយអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរៀបចំផែនការជាតិ រយៈពេលខ្លី មធ្យម និង វែង សំរាប់សកម្មភាពកំចាត់មីន។

**មាត្រា ៥.-**

អាជ្ញាធរមីន ត្រូវរៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលការណ៍ណែនាំ ថ្នាក់ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន នៅតាមខេត្តក្រុងពាក់ព័ន្ធ ។

**មាត្រា ៦.-**

គ្រប់សកម្មភាពបោសសំអាតមីន ដែលបានដាក់ចេញជាផែនការនៅក្នុងខេត្តក្រុងពាក់ព័ន្ធនីមួយៗ ត្រូវផ្ញើមកអាជ្ញាធរមីន ដើម្បីសម្រេចជាផ្លូវការមុនចាប់ផ្ដើមអនុវត្ត លើកលែងតែករណីចាំបាច់ ក្នុងទិសដៅអភិវឌ្ឍន៍មូលដ្ឋានបន្ទាន់បំផុត ដែលត្រូវអនុម័តដោយថ្នាក់ដឹកនាំខេត្តក្រុង រួចធ្វើសេចក្ដីរាយការណ៍មកអាជ្ញាធរមីនជាក្រោយ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវរបស់អាជ្ញាធរខេត្តក្រុង

**មាត្រា ៧.-**

អភិបាលខេត្តក្រុង ត្រូវទទួលខុសត្រូវ លើការជ្រើសរើសដីអាទិភាព សំរាប់ដោះមីននៅក្នុងដែនដីខេត្តក្រុងរបស់ខ្លួន ។

**មាត្រា ៨.-**

អភិបាលខេត្តក្រុង ត្រូវទទួលខុសត្រូវ រាល់សកម្មភាពបោសសំអាតមីននៅក្នុងដែនដីខេត្តក្រុង ដោយៈ

- អនុវត្តតាមយុទ្ធសាស្ត្រជាតិស្ដីពីសកម្មភាពកំចាត់មីន ដែលដាក់ចេញដោយអាជ្ញាធរមីន
- រៀបចំផែនការរបស់ខ្លួន ដោយអនុលោមតាមភាពចាំបាច់ជាក់ស្ដែង និង ផ្សារភ្ជាប់ជាមួយផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬ ខេត្តក្រុង ។

**មាត្រា ៩.-**

អភិបាលខេត្តក្រុង ត្រូវធានាលើដីដែលជ្រើសរើសសំរាប់ដោះមីន ត្រូវបែងចែក និងប្រើប្រាស់ឱ្យបានត្រឹមត្រូវ និង មានតម្លាភាព សមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ដោយឡែក នីតិវិធីនៃការបែងចែកដីជូនប្រជាពលរដ្ឋក្រីក្រ ដែលខ្វះដី និងគ្មានដី ត្រូវអនុលោមតាមអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ច និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ១០.-**

អភិបាលខេត្តក្រុង ត្រូវរៀបចំផែនការសកម្មភាពបោសសំអាតមីនប្រចាំឆ្នាំរបស់ខ្លួន ទៅតាមចំណាត់អាទិភាព រួចផ្ញើមកអាជ្ញាធរមីន។

**មាត្រា ១១.-**

អភិបាលខេត្តក្រុង ត្រូវចាត់វិធានការដោយរួសរាន់ លើរាល់សំណើលើកឡើងដោយ គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង។

**មាត្រា ១២.-**

អភិបាលខេត្តក្រុង ត្រូវរៀបចំបង្កើតយន្តការ ដែលជាបណ្តាញ ពិគ្រោះយោបល់ជាប្រចាំដើម្បីគ្រប់គ្រងសកម្មភាពកំចាត់មីនទាំងអស់ ក្នុងទិសដៅបង្កើនល្បឿនសកម្មភាពបោសសំអាតមីន និងកាត់បន្ថយអត្រាគ្រោះថ្នាក់ដោយសារមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះឱ្យបានជាអតិបរមា។

## ជំពូកទី ៤

## គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង

**មាត្រា ១៣.-**

អភិបាលខេត្តក្រុង ត្រូវបង្កើតគណៈកម្មាធិការសកម្មភាពកំចាត់មីន ក្នុងខេត្តក្រុងរបស់ខ្លួន ដោយប្រើប្រាស់ត្រារបស់ខេត្តក្រុងផ្ទាល់។ ដោយឡែកចំពោះអនុប្រធានអចិន្ត្រៃយ៍ អភិបាលខេត្តក្រុង ត្រូវជ្រើសរើសក្នុងចំណោមប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តក្រុង ប្រធានមន្ទីរផែនការខេត្តក្រុង និង ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រុង។

**មាត្រា ១៤.-**

គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង ត្រូវមានភារកិច្ចដូចតទៅ :

- ជ្រើសរើសដីចំការមីនសំរាប់បោសសំអាតអោយស្របទៅនឹង :
  - សមាហរណកម្មនៃយុទ្ធសាស្ត្រជាតិ ផែនការ និង អាទិភាពជាតិដទៃទៀត ដែលពាក់ព័ន្ធ
  - ធានានូវប្រសិទ្ធភាពនៃការផ្សារភ្ជាប់រវាងផែនការអភិវឌ្ឍខេត្តក្រុង និង ក្រុមប្រឹក្សាឃុំសង្កាត់

- ធ្វើអោយមានតម្លាភាពនៃដំណើរការដោះមីន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារដោះមីន និង អង្គការអភិវឌ្ឍនានា។

- ជ្រើសរើសដីចំការមីនអាទិភាពដោយ

  - អនុវត្តទៅតាមគោលការណ៍ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន ដែលចេញដោយអាជ្ញាធរមីន

  - សហការជាមួយគណៈកម្មាធិការបែងចែក និងប្រើប្រាស់ដីខេត្តក្រុង។

- សម្រេចផែនការប្រចាំឆ្នាំរបស់ខេត្តក្រុង ដោយ

  - រៀបចំផែនការអាទិភាពលំអិតមួយ ដែលទាក់ទងទៅនឹងផែនការបោសសំអាតមីនខេត្តក្រុង

  - ដាក់សេចក្តីព្រាងនោះជូនមកអាជ្ញាធរមីន។

**មាត្រា ១៥.-**

សមាសភាពនៃគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង រួមមាន:

| | |
|---|---|
| - អភិបាល ឬ អភិបាលរងខេត្តក្រុង | ប្រធាន |
| - ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី | អនុប្រធាន |
| - ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| - ប្រធានមន្ទីរផែនការ | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| - មេបញ្ជាការ នៃតំបន់ប្រតិបត្តិការសឹករង | សមាជិក |
| - ស្នងការនគរបាល | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថ | សមាជិក |
| - ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| - ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| - ប្រធានមន្ទីរកិច្ចការនារី | សមាជិក |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| - ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| - ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |

- ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ប្រធានមន្ទីរទេសចរណ៍ សមាជិក
- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- ប្រធានមន្ទីរធម្មការ និងសាសនា សមាជិក
- ប្រធានមន្ទីរពត៌មាន សមាជិក
- តំណាងយោធភូមិភាគ ឬកងពលដែលបោះទីតាំងក្នុងខេត្ត ក្រុង សមាជិក
- អភិបាលស្រុក ខ័ណ្ឌពាក់ព័ន្ធ សមាជិក
- ប្រធានការិយាល័យរដ្ឋបាលមូលដ្ឋាន សមាជិក
- ប្រតិបត្តិករដោះមីន ដែលធ្វើប្រតិបត្តិការក្នុងខេត្ត ក្រុង សមាជិក
- តំណាងភ្នាក់ងារអង្គការអន្តរជាតិ ដែលធ្វើប្រតិបត្តិការក្នុងខេត្ត ក្រុង សមាជិក

សមាសភាពនៃគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង ត្រូវបានតែងតាំងដោយអភិបាលខេត្តក្រុង លើកលែងតែតំណាងមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន ប្រតិបត្តិករដោះមីន និង តំណាងភ្នាក់ងារអង្គការអន្តរជាតិ ដែលនឹងត្រូវតែងតាំងដោយស្ថាប័នសាមី។

ប្រធាននៃគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង អាចអញ្ជើញតំណាងស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលមានសកម្មភាពពាក់ព័ន្ធ អោយចូលរួមជាសមាជិក ឬ សមាជិកសង្កេតការណ៍ ដោយផ្អែកលើតម្រូវការចាំបាច់ នៃសកម្មភាពបោសសំអាតមីននីមួយៗ។

**មាត្រា ១៦.-**

គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង ត្រូវបង្កើតក្រុមការងារបច្ចេកទេសអចិន្ត្រៃយ៍មួយជាសេនាធិការ និងមានក្រុមការងារច្រើនសំរាប់ប្រតិបត្តិការ នៅតាមសហគមន៍ដែលប៉ះពាល់ដោយសារមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

## ជំពូកទី ៥

## ក្រុមការងារផែនការសកម្មភាពកំចាត់មីន

**មាត្រា ១៧.-**

ក្រុមការងារផែនការសកម្មភាពកំចាត់មីន គឺជាក្រុមបច្ចេកទេសអចិន្ត្រៃយ៍ សំរាប់ជួយដល់គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។ ក្រុមការងារនេះ ត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង។

**មាត្រា ១៨.-**

សមាសភាពនៃក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវបានជ្រើសរើសក្នុងចំណោម មន្ត្រី-បុគ្គលិក មកពីស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ក្រុង ដែលជាសមាជិកនៃគណៈកម្មាធិការ សកម្មភាពកំចាត់មីនខេត្ត ក្រុង និង ភាគីពាក់ព័ន្ធដទៃទៀតក្នុងសកម្មភាពកំចាត់មីនខេត្ត ក្រុង។

**មាត្រា ១៩.-**

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវអនុវត្តនូវសេចក្តីសំរេចនានា ដែលចេញដោយគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។

**មាត្រា ២០.-**

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវពិនិត្យអង្កេតនៅតាមមូលដ្ឋានផ្ទាល់ ដើម្បីកំណត់ចំការមីនសំរាប់ដោះ ត្រួតពិនិត្យដំណើរការដោះមីន និងក្រោយពេលដោះមីន ស្របតាមគោលការណ៍ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន។

**មាត្រា ២១.-**

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវដាក់សំណើទៅគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្តក្រុង នូវផែនការការងារប្រចាំឆ្នាំពេញលេញមួយ ដោយរួមបញ្ចូលគ្រប់ផែនការសកម្មភាពបោសសំអាតមីននៅក្នុងខេត្ត ក្រុង។

**មាត្រា ២២.-**

ក្រុមការងារផែនការសកម្មភាពកំចាត់មីន ត្រូវរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។

## ជំពូកទី ៦

## ក្រុមការងារសកម្មភាពកំចាត់មីន ថ្នាក់ស្រុក ខ័ណ្ឌ

**មាត្រា ២៣.-**

ក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ ត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង។

**មាត្រា ២៤.-**

សមាសភាពនៃក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ រួមមានសមាជិកមកពីការិយាល័យពាក់ព័ន្ធជុំវិញស្រុក ខ័ណ្ឌ និង ភាគីពាក់ព័ន្ធនឹងសកម្មភាពបោសសំអាតមីនផ្សេងទៀត នៅក្នុងស្រុក ខ័ណ្ឌ ដោយមានអភិបាលស្រុក ខ័ណ្ឌ ជាប្រធាន។

**មាត្រា ២៥.-**

ក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ ត្រូវផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការជ្រើសរើសដីចំការមីន ដើម្បីកក្ខាប់ការបោសសំអាតមីន និង ដើម្បីជ្រើសរើស អ្នកទទួលផលឱ្យបានត្រឹមត្រូវទៅនឹងផែនការប្រើប្រាស់ដី។

**មាត្រា ២៦.-**

ក្រុមការងារសកម្មភាពកំចាត់មីនថ្នាក់ស្រុក ខ័ណ្ឌ ត្រូវដាក់សំណើផែនការការងារប្រចាំឆ្នាំ សំរាប់គ្រប់សកម្មភាពបោសសំអាតមីន ក្នុងស្រុក ខ័ណ្ឌ ទៅគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្រុង។

## ជំពូកទី ៧

## ប្រភពធនធាន

**មាត្រា ២៧.-**

ប្រភពធនធាន និង ថវិកាទ្រទ្រង់ដល់យន្តការសេដ្ឋកិច្ច-សង្គម សំរាប់ការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ត្រូវបានបង្កើតឡើងតាមរយៈ :

- ថវិកាជាតិ
- ប្រភពធនធានក្នុង និង ក្រៅប្រទេស ឬ បានមកពីអង្គការផ្តល់ជំនួយអន្តរជាតិនានា។

សេចក្តីលំអិតស្តីពីកិច្ចសំរបសំរួលហិរញ្ញវត្ថុ និងត្រូវមានចែងដោយឡែកនៅក្នុងគោលការណ៍ណែនាំសេដ្ឋកិច្ច-សង្គម ថ្នាក់ជាតិ ដូចមាននៅត្រង់មាត្រា ២៨ នៃអនុក្រឹត្យនេះ។

# ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨.-**

អាជ្ញាធរមីនត្រូវរៀបចំ និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលការណ៍ណែនាំថ្នាក់ជាតិផ្នែកសេដ្ឋកិច្ច-សង្គម សំរាប់សកម្មភាពបោសសំអាតមីន និង បទប្បញ្ញត្តិផ្សេងៗទៀត សំរាប់អនុវត្តអនុក្រឹត្យនេះ។

**មាត្រា ២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរមីន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត ក្រុងពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ដូចមាត្រា ១៥ និង ៣០*
*-ឯកសារ-កាលប្បវត្តិ*
*-រាជកិច្ច*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០០ ស្ដីពីការបញ្ចូលសមាសភាពឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ អនក្រ.បក ចុះថ្ងៃទី ខែ ឆ្នាំ ២០០៤ ស្ដីពីការកែប្រែមាត្រា ៤នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## សំរេច

**មាត្រា ១ ..**

សមាសភាពនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានរាយនាម ដូចតទៅ :

- ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- ឯកឧត្តម **ហេង វង្សប៊ុនឆាត** អនុប្រធាន នៃក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន
- ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
- ឯកឧត្តម **អ៊ិន ចន្ថា** រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
- ឯកឧត្តម **ជា សុផារ៉ា** រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ឯកឧត្តម **ប៊ុន អ៊ុយ** រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ឡុំ សុខា** រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ សមាជិក
- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ឡិក ប៊ុខ** រដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម សមាជិក
- ឯកឧត្តម **អ៊ិត ប្រាំង** រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- ឯកឧត្តម **អ៊ូ ឱឃាត** រដ្ឋលេខាធិការ នៃក្រសួងផែនការ សមាជិក
- ឯកឧត្តម **ឃិន គឹមស៊ាន** រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន សមាជិក
- ឯកឧត្តម **ង៉ោ ពិន** រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក
- ឯកឧត្តម **តាន់ ស៊ីថាន់** រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន សមាជិក
- ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការ នៃក្រសួង យុត្តិធម៌ សមាជិក
- ឯកឧត្តម **ឡាំ អ៊ុចតឹក** រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- ឯកឧត្តម **អ៊ិន ស៊ីយ៉ុន្ដា** រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ សមាជិក
- លោកជំទាវ **ឃីម ចំរើន** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី សមាជិក
- ឯកឧត្តម **ឱម យ៉ិនទៀង** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក
- ឯកឧត្តម **ឱច ស៊ិងតានណា** សមាជិកនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- ឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការ គណៈកម្មការជាតិវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

**មាត្រា ២ ..**

អនុក្រឹត្យ លេខ ៨០៥ អនក្រ.តត. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

គោលនយោបាយដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានសមាសភាពចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

អនុប្រធានអចិន្ត្រៃយ៍

**សុខ អាន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័ន
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្លាស់ប្តូរសមាសភាព តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន នៅក្នុងក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣៧៤ អនក្រ.តត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សម្រេច

**មាត្រា ១ .-**

ត្រូវបានតែងតាំង លោក **ហ៊្គី អានទ័រនិច** ជាសមាជិកថ្មី តំណាងក្រសួង សាធារណការ និង ដឹកជញ្ជូន ក្នុងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជំនួសឯកឧត្តម **សំ សុខ** ដែលត្រូវបាន បញ្ចប់ភារកិច្ច ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ខែ តុលា ឆ្នាំ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៤៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមសំណើរបស់លោកជំទាវទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំង លោក **សេ សុភ** ជាជំនួយការ លោកជំទាវ **ម៉ែន សំអន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត/០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងលោក **យឹម សុគន្ធី** ជាជំនួយការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

តែងតាំងលោក **សេខ ឃួត** ជាជំនួយការ សម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយករង ជំនួសលោក **ម៉ៅ រតនា** ដែលត្រូវបានទទួលតំណែងថ្មី ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៤៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយការងារ

※※※※※※

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ : ត្រូវបានប័ណ្ណាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នាយនគរបាល នាយនគរបាលរង និងពលនគរបាលចំនួន **១៩៧**រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម:

### ក / <u>មេដាយមាសការងារ ចំនួន ៧១ រូប</u>

១ - លោកឧត្តមសេនីយ៍ត្រី អ៊ុក សារ៉ូត ប្រធាននាយកដ្ឋានបំភ័ន្តអក្សរ

២ - លោកឧត្តមសេនីយ៍ត្រី គឹម ចាន់ទី ប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣ - លោកឧត្តមសេនីយ៍ត្រី ប្រុក សារឿន ប្រធានលេខាធិការដ្ឋានក្រុមអ្នកច្បាប់

៤ - លោកវរសេនីយ៍ឯក សោម សុភាព អនុប្រធានទី១ សេនាធិការដ្ឋាន

៥ - លោកវរសេនីយ៍ឯក ជុក គឹមហួរ អនុប្រធានទី១ នាយកដ្ឋានពត៌មានទូទៅ

៦ - លោកវរសេនីយ៍ឯក អៀង សាមីន អនុប្រធានទី១ នាយកដ្ឋានបំភ័ន្តអក្សរ

៧ - លោកវរសេនីយ៍ឯក គឹម សាវេទ អនុប្រធានទី១ ការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៨ - លោកវរសេនីយ៍ឯក ហ៊ឹម ផុន អនុប្រធានសេនាធិការដ្ឋាន

៩ - លោកវរសេនីយ៍ឯក យ៉េត វិរាហ្សាក់ អនុប្រធានសេនាធិការដ្ឋាន

១០ - លោកវរសេនីយ៍ឯក ភួង ម៉ាលែ អនុប្រធានលេខាធិការដ្ឋាន

១១ - លោកវរសេនីយ៍ឯក ឆាយ គឹមឡៀង អនុប្រធានលេខាធិការដ្ឋាន

១២ - លោកវរសេនីយ៍ឯក ម៉ៅ និម្មល ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

១៣ - លោកវរសេនីយ៍ឯក ឡាយ យិន ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន

១៤ - លោកវរសេនីយ៍ឯក កង់ ធន្និ ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលមធ្យោបាយ

១៥ - លោកវរសេនីយ៍ឯក ប៊ុក សុខន អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ

១៦ - លោកវរសេនីយ៍ឯក ប្រាក់ កាណារ៉ា អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

១៧ - លោកវរសេនីយ៍ឯក ចេង សុវណ្ណ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

១៨ - លោកវរសេនីយ៍ឯក ហ៊ូ សេងលន់ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

១៩ - លោកវរសេនីយ៍ឯក ថោង សំអាត អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

២០ - លោកវរសេនីយ៍ឯក ធិន្ទ សុវណ្ណា អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

២១ - លោកវរសេនីយ៍ឯក ទូច ង៉ែម អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

២២ - លោកវរសេនីយ៍ឯក ចោម ប៊ុនសេង អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ

២៣ - លោកវរសេនីយ៍ឯក ខៀវ សុធា អនុប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម

២៤ - លោកវរសេនីយ៍ឯក កុល គឹមលី អនុប្រធាននាយកដ្ឋានស្ថាបនា

២៥ - លោកវរសេនីយ៍ឯក អ៊ុម ម៉ុង អនុប្រធាននាយកដ្ឋានស្ថាបនា

២៦ - លោកវរសេនីយ៍ឯក ប៉ែ ស៊ីរី អនុប្រធាននាយកដ្ឋានស្ថាបនា

២៧ - លោកវរសេនីយ៍ឯក យ៉ែម ម៉ៅ អនុប្រធាននាយកដ្ឋានបំភ័ន្តអក្ខរៈ

២៨ - លោកវរសេនីយ៍ឯក ឡុង វិចិត្រ អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន

២៩ - លោកវរសេនីយ៍ឯក ជោត សំរ៉ាំង អនុប្រធានលេខាធិការដ្ឋានក្រុមអ្នកច្បាប់

៣០ - លោកវរសេនីយ៍ឯក ឡាំ ប៊ុនថារ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣១ - លោកវរសេនីយ៍ឯក អ៊ិន សារិន អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣២ - លោកវរសេនីយ៍ឯក កែវ វណ្ណថន អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣៣ - លោកវរសេនីយ៍ឯក ពេជ្រ គុង អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣៤ - លោកវរសេនីយ៍ឯក សំ បូរ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ

៣៥ - លោកវរសេនីយ៍ឯក ឡុង លឹម ស្នងការនគរបាលខេត្តស្ទឹងត្រែង

៣៦ - លោកវរសេនីយ៍ទោ បក់ ចាន់សិទ្ធី នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

៣៧ - លោកវរសេនីយ៍ទោ វ៉ាន់ សារិទ្ធ នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

៣៨ - លោកវរសេនីយ៍ទោ ខៀវ ចាន់រ៉ា ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៣៩ - លោកវរសេនីយ៍ទោ ជីវ ផល្លី ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៤០ - លោកវរសេនីយ៍ទោ យុត សុធា ជំនួយការប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

| | | | | |
|---|---|---|---|---|
| ៤១ - | លោកវរសេនីយ៍ទោ | ជា | យឿន | ជំនួយការប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ |
| ៤២ - | លោកវរសេនីយ៍ទោ | ហេង | រត្នសីមា | នាយការិយាល័យ នៃលេខាធិការដ្ឋានក្រុមរក្សាច្បាប់ |
| ៤៣ - | លោកវរសេនីយ៍ទោ | ហាក់ | គីមរ៉ុង | នាយការិយាល័យ នៃការិយាល័យកណ្តាលនគរបាលអន្តរជាតិ |
| ៤៤ - | លោកវរសេនីយ៍ទោ | រស់ | សុខា | នាយការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៤៥ - | លោកវរសេនីយ៍ទោ | ប៊ុំ | មិត្តសុផាន | នាយការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| ៤៦ - | លោកវរសេនីយ៍ទោ | ងួន | គឿន | ស្នងការរងទី១ នគរបាលខេត្តស្ទឹងត្រែង |
| ៤៧ - | លោកវរសេនីយ៍ត្រី | នង | សារិន | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៤៨ - | លោកវរសេនីយ៍ត្រី | ឈឹម | រ៉ានី | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៤៩ - | លោកវរសេនីយ៍ត្រី | ប៊ុង | បូរ៉ា | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥០ - | លោកវរសេនីយ៍ត្រី | ស្មាន់ | សារឿន | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥១ - | លោកវរសេនីយ៍ត្រី | ឱ | សំណាង | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥២ - | លោកវរសេនីយ៍ត្រី | សួរ | វេងលាង | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥៣ - | លោកវរសេនីយ៍ត្រី | ម៉ៅ | វ៉ាន់ដា | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥៤ - | លោកវរសេនីយ៍ត្រី | លាង | សេងហាន | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥៥ - | លោកវរសេនីយ៍ត្រី | អៀម | បូណារ័ត្ន | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥៦ - | លោកវរសេនីយ៍ត្រី | ឈឹម | ផន | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥៧ - | លោកវរសេនីយ៍ត្រី | ចាន់ | សុខហេង | នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ៥៨ - | លោកវរសេនីយ៍ត្រី | កែ | ខាន់ណារ៉ា | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ |
| ៥៩ - | លោកវរសេនីយ៍ត្រី | ឡុង | សុគន្ធ | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ |
| ៦០ - | លោកវរសេនីយ៍ត្រី | មាស | ចាន់ថន | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ |
| ៦១ - | លោកវរសេនីយ៍ត្រី | ឯម | សារិទ្ធ | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ |
| ៦២ - | លោកវរសេនីយ៍ត្រី | លន | ណារឡាម | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ |
| ៦៣ - | លោកវរសេនីយ៍ត្រី | កែវ | បួរ | នាយរងការិយាល័យកណ្តាល នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ |
| ៦៤ - | លោកវរសេនីយ៍ត្រី | ង៉ែត | សូគីម | នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| ៦៥ - | លោកវរសេនីយ៍ត្រី | ស្រី | សុខា | នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| ៦៦ - | លោកវរសេនីយ៍ត្រី | គួន | សុគន្ធ | នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| ៦៧ - | លោកវរសេនីយ៍ត្រី | អេង | វុទ្ធី | នាយរងការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| ៦៨ - | លោកវរសេនីយ៍ត្រី | ធុច | ខេមរិន្ទ | អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ៦៩ - | លោកវរសេនីយ៍ត្រី | ចាន់ | បូរ៉ាន់ | ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ៧០ - | លោកវរសេនីយ៍ត្រី | លឹម | វណ្ណធី | ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ៧១ - | លោកអនុសេនីយ៍ឯក | ណុប | សុផល | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |

ក / មេដាយថ្នាក់ការងារ ចំនួន ១០០ រូប

១ - លោកវរសេនីយ៍ឯក គីម ម៉ែតសុពល អនុប្រធាននាយកដ្ឋានបំភ័ន្តអក្សរ

២ - លោកវរសេនីយ៍ឯក ឌុច ឡឿន អនុប្រធាននាយកដ្ឋានបំភ័ន្តអក្សរ

៣ - លោកវរសេនីយ៍ទោ តាន់ ប៉េងហៀង ជំនួយការប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ

៤ - លោកវរសេនីយ៍ទោ គីប សារ៉េន អនុប្រធានអង្គភាព នៃសេនាធិការដ្ឋាន

៥ - លោកវរសេនីយ៍ទោ ម៉ុល វណ្ណធឿន នាយការិយាល័យ នៃសេនាធិការដ្ឋាន

៦ - លោកវរសេនីយ៍ទោ គិន ឡាយ នាយការិយាល័យ នៃសេនាធិការដ្ឋាន

៧ - លោកវរសេនីយ៍ទោ ឃី សាហ៊ឿន នាយការិយាល័យ នៃសេនាធិការដ្ឋាន

៨ - លោកវរសេនីយ៍ទោ យុង សំខាន់ នាយការិយាល័យ នៃសេនាធិការដ្ឋាន

៩ - លោកវរសេនីយ៍ទោ ហេង សៀប នាយការិយាល័យ នៃការិយាល័យកណ្តាលនគរបាលអន្តរជាតិ

១០ - លោកវរសេនីយ៍ទោ ជា សុវណ្ណសុខ នាយការិយាល័យ នៃការិយាល័យកណ្តាលនគរបាលអន្តរជាតិ

១១ - លោកវរសេនីយ៍ទោ យិន យឿន នាយការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្សរ

១២ - លោកវរសេនីយ៍ទោ ខួង គីបសាន្ត នាយការិយាល័យ នៃនាយកដ្ឋានបំភ័ន្តអក្សរ

១៣ - លោកវរសេនីយ៍ទោ ទូ សារិទ្ធ នាយការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ

១៤ - លោកវរសេនីយ៍ទោ ស៊ុន រ៉ូ នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

១៥ - លោកវរសេនីយ៍ទោ ចោង គីមហេង នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

១៦ - លោកវរសេនីយ៍ទោ ព្រុំ វុត្ថា នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

១៧ - លោកវរសេនីយ៍ទោ កែប សារឿន នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

១៨ - លោកវរសេនីយ៍ទោ បង្ស សុផាណារ៉ា នាយការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

១៩ - លោកវរសេនីយ៍ត្រី យិន តា នាយរងការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

២០ - លោកវរសេនីយ៍ត្រី ភេម កុង អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

២១ - លោកវរសេនីយ៍ត្រី ម៉ុល រិទ្ធិ អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

២២ - លោកវរសេនីយ៍ត្រី ហេង សុវត្ថិ នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

២៣ - លោកវរសេនីយ៍ត្រី វ៉ាន់ ឡាយ នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

២៤ - លោកវរសេនីយ៍ត្រី ប្រុក ម៉ៃឧត្តម នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់

២៥ - លោកវរសេនីយ៍ត្រី រស់ សាផល នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់

២៦ - លោកវរសេនីយ៍ត្រី ប្រាក់ ពៅ នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់

២៧ - លោកវរសេនីយ៍ត្រី ជឹម ថា នាយរងការិយាល័យ នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់

២៨ - លោកវរសេនីយ៍ត្រី ភួង សុភី នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

២៩ - លោកវរសេនីយ៍ត្រី យ៉យ យួន នាយរងការិយាល័យ នៃនាយកដ្ឋានសណ្តាប់ធ្នាប់

| | | | | |
|---|---|---|---|---|
| ៣០ | លោកវរសេនីយ៍ត្រី | អ៊ុក | គឹមកាម៉ារ៉ា | នាយរងការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រឿងភ័ណ្ឌ |
| ៣១ - | លោកវរសេនីយ៍ត្រី | កង | សោភ័ទ្រ | នាយរងការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រឿងភ័ណ្ឌ |
| ៣២ - | លោកវរសេនីយ៍ត្រី | ម៉ុន | ម៉េ | នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ |
| ៣៣ | លោកវរសេនីយ៍ត្រី | រ៉ែ | សារុត | នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ |
| ៣៤ - | លោកវរសេនីយ៍ត្រី | ហ៊ុន | លីមហាក់ | នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ |
| ៣៥ - | លោកវរសេនីយ៍ត្រី | កង់ | តែស៊ុម | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង |
| ៣៦ - | លោកវរសេនីយ៍ត្រី | រំព្រក | សុខន | នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង |
| ៣៧ - | លោកវរសេនីយ៍ត្រី | ហេង | ដាណេក់ | នាយរងការិយាល័យរដ្ឋបាល នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង |
| ៣៨ - | លោកអនុសេនីយ៍ឯក | សំ | សារិទ្ធ | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៣៩ - | លោកអនុសេនីយ៍ឯក | ដួ | សុគីម | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤០ - | លោកអនុសេនីយ៍ឯក | ប៉ុល | សម្បត្តិ | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤១ - | លោកអនុសេនីយ៍ឯក | ទេព | ស៊ុន | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤២ - | លោកអនុសេនីយ៍ឯក | ពៅ | សារឿន | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៣ - | លោកអនុសេនីយ៍ឯក | លី | ទីន | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៤ - | លោកអនុសេនីយ៍ឯក | សូ | បារាំង | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៥ - | លោកអនុសេនីយ៍ឯក | អ៊ុក | ញ៉ែម | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៦ | លោកអនុសេនីយ៍ឯក | ហ៊ាន | លី | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៧ - | លោកអនុសេនីយ៍ឯក | ផាន់ | ម៉ុង | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៨ - | លោកអនុសេនីយ៍ឯក | ប្រាក់ | សុផានិត | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៤៩ - | លោកអនុសេនីយ៍ឯក | ឥង | សម្បត្តិ | នាយផ្នែក នៃនាយកដ្ឋានបុគ្គលិក |
| ៥០ - | លោកអនុសេនីយ៍ឯក | ឃុន | មង្គល | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥១ - | លោកអនុសេនីយ៍ឯក | សេក | វណ្ណា | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥២ - | លោកអនុសេនីយ៍ឯក | ទូច | ពល: | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥៣ - | លោកអនុសេនីយ៍ឯក | ស៊ុន | គឹមស៊ា | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥៤ - | លោកអនុសេនីយ៍ឯក | យូ | រី | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥៥ | លោកអនុសេនីយ៍ឯក | ស៊ិន | ដារ៉ូ | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥៦ | លោកអនុសេនីយ៍ឯក | អៀ | ខេង | មេបញ្ជាការរងវរសេនាតូចការពារព្រំដែន នៃនាយកដ្ឋាននគរបាលព្រំដែនទឹក |
| ៥៧ - | លោកអនុសេនីយ៍ឯក | អៀវ | ប៊ុនឡេង | នាយផ្នែក នៃនាយកដ្ឋានកណ្តាលនគរបាលយុត្តធម៌ |
| ៥៨ - | លោកអនុសេនីយ៍ឯក | លន់ | រី | នាយផ្នែក នៃលេខាធិការដ្ឋានក្រុមអ្នកច្បាប់ |
| ៥៩ - | លោកអនុសេនីយ៍ឯក | ជា | ហេង | នាយផ្នែក នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ៦០ - | លោកអនុសេនីយ៍ឯក | ភិន | ចាវុធ | នាយផ្នែក នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន |

៦១ - លោកស្រីអនុសេនីយ៍ឯក ទិត សិរការី នាយផ្នែក នៃនាយកដ្ឋានកណ្តាលសេវាប្រាប់ថ្នាក់សាធារណៈ

៦២ - លោកអនុសេនីយ៍ឯក ឡាក់ ប៊ុន នាយផ្នែក នៃនាយកដ្ឋានកណ្តាលសេវាប្រាប់ថ្នាក់សាធារណៈ

៦៣ - លោកអនុសេនីយ៍ឯក ម៉ក សុផា នាយផ្នែក នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

៦៤ - លោកអនុសេនីយ៍ឯក អៀង សុផានី នាយផ្នែក នៃនាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ

៦៥ - លោកអនុសេនីយ៍ឯក ជុំ សាមុន នាយផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ

៦៦ - លោកស្រីអនុសេនីយ៍ឯក នេត ធីតា នាយផ្នែក នៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ

៦៧ - លោកអនុសេនីយ៍ឯក ពេជ ភារីនី នាយផ្នែក នៃនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ

